# កិច្ចការពារកុមារ – គោលនយោបាយសង្ខេប ២០១៥

World Vision

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចគួរឱ្យកត់សម្គាល់ក្នុងការបង្កើតនូវក្របខណ្ឌគតិយុត្តិនិងគោលនយោបាយដើម្បីការពារកុមារ រួមមានយន្តការនានានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តច្បាប់ និងគោលនយោបាយព្រមទាំងគណនេយ្យភាពរបស់យន្តការថ្នាក់មូលដ្ឋាននៅមានកម្រិត និងនៅបន្តធ្វើឱ្យកុមារស្ថិតក្នុងហានិភ័យនៅឡើយ។

## អនុសាសន៍សំខាន់ៗ៖

**អង្គការទស្សនៈពិភពលោកសូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ៖**

- ពង្រឹងយន្តការការពារកុមារដែលមានស្រាប់តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបង្កើននូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដល់ស្ថាប័នថ្នាក់មូលដ្ឋាន។
- ធ្វើឱ្យកាន់តែច្បាស់នូវខ្លឹមសារច្បាប់ គោលនយោបាយ បទដ្ឋាន និងបទបញ្ញា ទាក់ទងនឹងការការពារកុមារដែលមានស្រាប់ និងមានការអនុវត្តប្រសើរជាងមុន។

## ស្ថានភាពបច្ចុប្បន្នរបស់កុមារក្នុងប្រទេសកម្ពុជា

បើយោងទៅតាមអង្គការយូនីសេហ្វ មានកុមារកំព្រា និងកុមារងាយរងគ្រោះ ប្រហែល១លាន៥សែននាក់កំពុងរស់នៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានកុមាររហូតដល់ពីរសែននាក់កំពុងរស់នៅ ឬធ្វើការនៅតាមផ្លូវក្នុងទីក្រុងភ្នំពេញ។ កុមារទាំងនេះមួយចំនួនជាជនរងគ្រោះដោយការបង្ខំឱ្យធ្វើការ និងការជួញដូរ ហើយមួយចំនួនទៀតទទួលរងគ្រោះដោយអំពើហឹង្សា ឬការរំលោភបំពាន ឬមានពិការភាព។ [1] ការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១៣បានបង្ហាញថា អំពើហឹង្សាទៅលើកុមារផ្នែករាងកាយ ផ្លូវភេទ និងផ្លូវចិត្ត មានកម្រិតខ្ពស់ ដោយមានកុមារា និងកុមារីច្រើនជាងពាក់កណ្តាល បានរាយការណ៍ថា ពួកគេធ្លាប់ទទួលរងការរំលោភបំពានផ្នែករាងកាយមួយលើកមុនដែលពួកគេមានអាយុ១៨ឆ្នាំ។[2] ប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា កំពុងមានការវិវឌ្ឍ តែមិនទាន់អាចឆ្លើយតបឱ្យបានពេញលេញទៅនឹងតម្រូវការរបស់កុមារដែលប្រឈមមុខនឹងច្បាប់នៅឡើយ ទោះបីគេជាជនរងគ្រោះ សាក្សី ឬជនសង្ស័យយ៉ាងណាក្តី។ [3] នីតិវិធីនិងបរិក្ខារចាំបាច់សម្រាប់ដោះស្រាយជាមួយអនីតិជនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកំពុងនៅមានការខ្វះខាត។ ដូច្នេះកុមារតែងតែទទួលចំណាត់ការតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងទទួលការកាត់ទោសដូចនីតិជនដែរ។ [4] នៅក្នុងឆ្នាំ២០០៩ មានកុមារប្រហែល ៨២៦នាក់ នៅក្នុងមន្ទីរឃុំឃាំង បើប្រៀបធៀបទៅនឹង ចំនួន ៦៣០ នាក់ ក្នុងឆ្នាំ២០០៧ និង ៤៩៣នាក់ ក្នុងឆ្នាំ២០០៦។[5] លើសពីនេះទៅទៀត ពុំទាន់មានយន្តការឯករាជ្យណាមួយដើម្បីទទួលនិងដោះស្រាយបណ្តឹងរបស់កុមារទាក់ទងនឹងការរំលោភបំពានសិទ្ធិរបស់ពួកគេនៅឡើយ។[6]

- **ពលកម្មកុមារ**

បើយោងទៅតាមវិទ្យាស្ថានជាតិស្ថិតិ ក្នុងចំណោមកុមារប្រហែល៧៥៥.២៤៥នាក់ដែលចូលរួមយ៉ាងសកម្មផ្នែកសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាឆ្នាំ២០១២ មានចំនួន ៥៦,៩% (៤២៩.៣៨០នាក់) គឺជាកុមារពលករ ហើយ ៣១,៣% (២៣៦.៤៩៨នាក់) គឺជាកុមារស្ថិតនៅក្នុងការងារគ្រោះថ្នាក់។ ដូច្នេះកុមារពលករប្រាំនាក់ក្នុងចំណោមប្រាំបួននាក់ ជាប់ពាក់ព័ន្ធក្នុងការងារគ្រោះថ្នាក់។[7]

- **ការជួញដូរកុមារ និងការរំលោភបំពានផ្លូវភេទ**

នៅក្នុងឆ្នាំ២០១០ របាយការណ៍ទិន្នន័យស្ថិតិរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនានាស្តីពីការរំលោភសេពសន្ថវៈ ជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ បានរកឃើញមានការជួញដូរផ្លូវភេទ៣៩ករណី ដោយមានការជាប់ពាក់ព័ន្ធជនសង្ស័យជួញដូរផ្លូវភេទចំនួន ៦១នាក់។ ៥៦,៤% នៃជនរងគ្រោះមានអាយុក្រោម១៨ឆ្នាំ។ នៅក្នុងឆ្នាំ២០១១ មានករណីជួញដូរផ្លូវភេទចំនួន៧១ករណីត្រូវបានរាយការណ៍ ដែលក្នុងនោះ ៧៥%ពាក់ព័ន្ធនឹងកុមារ។ តាមរយៈទិន្នន័យដែលមានក្នុងឆ្នាំ២០១១ ក្នុងចំណោមការជួញដូរផ្លូវភេទចំនួន ៣៣ករណី មាន ១៧ករណីត្រូវបានស៊ើបអង្កេតដោយប៉ូលីស ហើយមាន ៣ករណីបានឈានទៅដល់ការកាត់ក្តីផ្នែកព្រហ្មទណ្ឌ។[8]

## ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាកិច្ចការពារកុមារ

នៅក្នុងឆ្នាំ១៩៩២ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិ១៨ផ្សេងទៀត ច្បាប់ក្នុងស្រុកចំនួន១៥ រួមទាំងគោលនយោបាយនិងអនុក្រឹត្យមួយចំនួនដែលពាក់ព័ន្ធនឹងការការពារកុមារ។[9] មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ក៏បានទទួលស្គាល់សិទ្ធិកុមារដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ និងសេរីភាពរួចផុតពីការការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬផ្លូវភេទផងដែរ។[10] លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានបង្កើតយន្តការនិងយុទ្ធសាស្ត្រផ្សេងៗនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីបង្កើតឱ្យមានប្រព័ន្ធការពារកុមារមួយនៅក្នុងប្រទេសកម្ពុជា ក្នុងនោះរួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ (គ.ក.ន.ក) ព្រមទាំងអន្តរាគមន៍ផ្សេងៗទៀតសំដៅការពារកុមារស្ថិតនៅក្នុងការថែទាំក្នុងមណ្ឌល ដូចជាគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារដែលបានអនុម័តក្នុងឆ្នាំ២០០៦។

ក្នុងការឆ្លើយតបទៅនឹងបញ្ហាពលកម្មកុមារនិងការជួញដូរកុមារ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់មួយចំនួនរួមមាន ផែនការជាតិស្តីពីការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ២០០៨-២០១២ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ ២០០៨[11] គោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ២០១០ និង ផែនការជាតិប្រឆាំងនឹងការជួញដូរមនុស្ស ២០១៤-២០១៨។ សេចក្តីព្រាងច្បាប់យុត្តិធម៌សម្រាប់អនីតិជនបានរៀបចំឡើងតាំងពីឆ្នាំ២០០២ ដើម្បីការពារកុមារដែលពាក់ព័ន្ធនឹងច្បាប់ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះមិនទាន់បានបញ្ចប់នៅឡើយ ហើយនៅតែជាក្របខណ្ឌច្បាប់ចាំបាច់បំផុត។[12]

## ភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធការពារកុមារបច្ចុប្បន្ន

បើទោះបីជាមានក្របខណ្ឌច្បាប់និងយន្តការការពារកុមារជាច្រើននៅក្នុងប្រទេសក៏ដោយ ភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធបច្ចុប្បន្នទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ បានធ្វើឱ្យការការពារកុមារក្នុងប្រទេសកម្ពុជាមិនបានពេញលេញនិងមានប្រសិទ្ធិភាពនៅឡើយ។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យសិទ្ធិកុមារ មានការរួមចំណែកក្នុងការបង្កើតគោលនយោបាយ ច្បាប់ និងយុទ្ធសាស្ត្រទាក់ទងនឹងកុមារនៅមានកម្រិតនៅឡើយ ថ្វីត្បិតតែពួកគេដើរតួនាទីសំខាន់និងមានជំនាញក្នុងការលើកកម្ពស់និងការពារសិទ្ធិរបស់កុមារក៏ដោយ។[13] ពាក់ព័ន្ធនឹងយន្តការអនុវត្តវិញ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដែលជាយន្តការសម្របសម្រួលថ្នាក់ជាតិសម្រាប់ការអនុវត្ត ការពិចារណា និងការវាយតម្លៃនូវគ្រប់គោលនយោបាយនិងកម្មវិធីពាក់ព័ន្ធនឹងកុមារកម្ពុជា នៅមានភាពខ្វះខាតនូវធនធានមនុស្ស បច្ចេកទេស និងថវិកា

ចាំបាច់សម្រាប់អនុវត្តតួនាទីសម្របសម្រួលរបស់ខ្លួននៅឡើយ។ [14] ស្ថាប័នរដ្ឋាភិបាលនៅពុំទាន់មានកាតព្វកិច្ចក្នុងការបញ្ជូនឬរាយការណ៍បញ្ហានានាទាក់ទងនឹងសិទ្ធិរបស់កុមារទៅកាន់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅឡើយ។[15] លើសពីនេះទៅទៀត ការសម្របសម្រួលថ្នាក់ជាតិ ខេត្ត និងស្រុកក្នុងចំណោមក្រសួងដែលមានមុខងារការពារកុមារ នៅមានភាពទន់ខ្សោយ [16] ហើយបញ្ហាកិច្ចការពារកុមារកម្រនឹងត្រូវបានបញ្ចូលក្នុងផែនការវិនិយោគឃុំ សង្កាត់ណាស់។ ភាគច្រើននៃថវិការបស់ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានចំណាយលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហើយថវិកាតិចតួចប៉ុណ្ណោះដែលផ្តោតទៅលើសេវាកម្មសង្គមសម្រាប់កុមារនិងស្ត្រី។ [17] គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ដែលត្រូវបានបង្កើតឡើងទូទាំងប្រទេសដើម្បីជានានូវកិច្ចការពារកុមារនៅថ្នាក់មូលដ្ឋាន ពុំមានថវិកាគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួន ហើយភាគច្រើនពុំទាន់យល់ច្បាស់លាស់នូវតួនាទីនិងភារកិច្ចរបស់ខ្លួននៅឡើយ។ សមាជិករបស់ គណៈកម្មាធិការនេះ មានសមត្ថភាពនៅមានកម្រិតក្នុងការរៀបចំផែនការថវិកា និងការដាក់បញ្ចូលបញ្ហាកិច្ចការពារកុមារទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ហើយខ្វះនូវជំនាញចាំបាច់សម្រាប់កំណត់រកកុមារងាយរងគ្រោះបំផុតនៅក្នុងឃុំសង្កាត់របស់ពួកគេ។

បញ្ហាប្រឈមនៅថ្នាក់មូលដ្ឋានទាំងនេះ កាន់តែមានភាពធ្ងន់ធ្ងរដោយសារការអនុវត្តច្បាប់និងគោលនយោបាយជាតិពុំមានប្រសិទ្ធភាព។ ជាឧទាហរណ៍ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញថា នៅក្នុងឆ្នាំ២០១០ ពុំមាននិយោជកណាម្នាក់ត្រូវបានកាត់ទោសដោយសារការរំលោភបំពានច្បាប់ពាក់ព័ន្ធនឹងពលកម្មកុមារឡើយ [18] ហើយមានសំណួរជាច្រើនសួរថាតើច្បាប់អាចអនុវត្តបានដែរឬទេបើធនធាននិងសមត្ថភាពអ្នកអនុវត្តច្បាប់មានកម្រិត។ [19] ដូចគ្នានេះដែរ ការអនុវត្តនូវច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទបានបង្ហាញថាពុំមានប្រសិទ្ធភាព។ របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៣ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិច បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានខកខានក្នុងការចាប់អ្នកជួញដូរផ្លូវភេទនិងអ្នកទេសចរណ៍ផ្លូវភេទកុមារឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ពីព្រោះពុំមានការកាត់ក្តីនិងផ្តន្ទាទោសគ្រប់គ្រាន់។ [20] ច្បាប់ស្តីពីអនីតិជនមានទំនាស់នឹងក្រមព្រហ្មទណ្ឌស្ថិតនៅជាសេចក្តីព្រាងច្បាប់នៅឡើយ ហើយការប្រើប្រាស់ក្រមព្រហ្មទណ្ឌបច្ចុប្បន្នដើម្បីការពារអនីតិជនគឺមានភាពទន់ខ្សោយនៅឡើយ ជួនកាលដោយសារការខ្វះនូវឯកសារបញ្ជាក់នូវអាយុរបស់កុមារ ដោយសារទេសន្តរប្រវេសន៍ក្នុងស្រុក ការបណ្តេញចេញដោយបង្ខំ ឬការខកខានមិនបានផ្តល់ឯកសារចុះបញ្ជីកំណើត។[21]

## ជាការឆ្លើយតបនឹងបញ្ហាកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោក សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ៖

**ពង្រឹងយន្តការការពារកុមារដែលមានស្រាប់នៅថ្នាក់ក្រោមជាតិ ហើយបង្កើនការសម្របសម្រួលយន្តការទាំងនេះនៅថ្នាក់ជាតិ។**

- ផ្តល់នូវមុខងារនិងតួនាទីដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ឱ្យបានច្បាស់លាស់ជាងមុន ហើយនិងផ្តល់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់សមាជិកគណៈកម្មាធិការនេះដើម្បីធ្វើឱ្យការប្រតិបត្តិការងារនិងប្រសិទ្ធភាពការងាររបស់ពួកគេមានភាពប្រសើរឡើង រួមមានការដាក់បញ្ចូលកិច្ចការពារកុមារនិងផ្តល់ថវិកានៅក្នុងផែនការវិនិយោគឃុំ។
- ផ្តល់នូវភារកិច្ចច្បាស់លាស់ដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងផ្តល់ធនធានមនុស្សបច្ចេកទេស និងថវិកាបន្ថែម។ ទំនាក់ទំនងរវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួង ស្ថាប័ន

នានារបស់រដ្ឋាភិបាលគួរតែបញ្ជាក់ឱ្យបានច្បាស់និងធ្វើឱ្យបានប្រសើរឡើង ដើម្បីធានាថាបញ្ហាកិច្ចការពារកុមារ ត្រូវបានរាយការណ៍ទៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

- បញ្ចូលការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ស្ថាប័នថ្នាក់ក្រោមជាតិ ទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់រដ្ឋាភិបាលឱ្យបានច្រើនជាងមុនរួមមានការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចល្អ និងគណនេយ្យភាព ហើយធ្វើការពិភាក្សាបន្ថែមទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលដែលមានប្រសិទ្ធភាព។
- ធ្វើឱ្យការសម្របសម្រួលរវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងភាគីពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ មានភាពប្រសើរឡើងតាមរយៈផែនការសកម្មភាព។

## ធ្វើឱ្យមានភាពប្រសើរជាងមុននូវការអនុវត្តច្បាប់ គោលនយោបាយ បទដ្ឋាន និងបទបញ្ញាទាក់ទងនឹងកិច្ចការពារកុមារ។

- រកឱ្យឃើញនូវភាពខ្វះចន្លោះ និងភាពមានកម្រិតរបស់ច្បាប់ គោលនយោបាយ បទបញ្ញា និងបទដ្ឋាន ហើយធ្វើវិសោធនកម្មភាពខ្វះខាតទាំងនោះតាមរយៈការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលដើម្បីឱ្យការអនុវត្តមានភាពប្រសើរឡើង។
- ធ្វើការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការទាក់ទងនឹងសិទ្ធិរបស់កុមារ ដើម្បីផ្តល់នូវគោលការណ៍ណែនាំ ដល់ភ្នាក់ងារអនុវត្តច្បាប់ ដូចជា ប៉ូលីស និងចៅក្រមដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានកុមារបានប្រសើរជាងមុន។
- ធ្វើឱ្យមានការចូលរួមជាប្រព័ន្ធពីសំណាក់ប្រជាពលរដ្ឋជាពិសេសកុមារនិងយុវជនដើម្បីចូលរួមនិងត្រួតពិនិត្យការអនុវត្ត នូវគោលនយោបាយនិងកម្មវិធីពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារនៅថ្នាក់មូលដ្ឋាន។
- បង្កើតប្រព័ន្ធទិន្នន័យអ៊ីនធឺណែតថ្នាក់ជាតិយ៉ាងទូលំទូលាយមួយស្តីពី ពលកម្មកុមារ ការជួញដូរកុមារ និងការរំលោភបំពានផ្លូវភេទ ដើម្បីតាមដាននូវវឌ្ឍនភាពនៃកិច្ចការពារកុមារ ហើយរៀបចំព័ត៌មានទាំងនោះ ឱ្យសាធារណៈជនបានដឹង ដើម្បីគាំទ្រដល់អង្គការធ្វើការលើវិស័យសិទ្ធិកុមារ និងក្រុមប្រជាពលរដ្ឋធ្វើការការពារកុមារនិងបង្ការការរំលោភបំពានបានប្រសើរជាងមុន។

---

[1] UNICEF. *Child Protection*. Available at http://www.unicef.org/cambodia/2.Child_Protection.pdf
[2] Findings from Cambodia's Violence Against Children Survey 2013: Summary, MoWA, UNICEF and CDC (2014).
[3] UNICEF. *Child Protection.*
[4] NGOCRC (2013). *UPR Submission on Cambodia Child Rights.*
[5] UNICEF. *Child Protection.*
[6] NGOCRC (2013). *UPR Submission on Cambodia Child Rights.*
[7] National Institute of Statistics (2013). *Cambodia Labor Force and Child Labor Survey 2012: Child Labor Report.*
[8] Ibid.
[9] World Vision (2014). *Technical Approach for Child Protection (LEAP 3.0).*
[10] RGC. *Constitution of Cambodia (amended in 1999).*
[11] NGOCRC (2013). *UPR Submission on Cambodia Child Rights.*
[12] NGOCRC. *Expert Meets to Discuss Draft Juvenile Justice Law* (extracted from Phnom Penh Post, 14 December 2010), available at http://ngocrc.org/en/news/latest-news/1-latest-news/186.pdf
[13] UNCRC (2011). *Concluding Observations: Cambodia.* CRC/C/KHM/CO/2-3.
[14] Ibid.
[15] Ibid.
[16] World Vision (2014). *Technical Approach for Child Protection (LEAP 3.0).*
[17] UNICEF. *Local Governance for Child Rights*. Available at http://www.unicef.org/cambodia/5.LGCR.pdf
[18] NGOCRC (2013). *UPR Submission on Cambodia Child Rights.*
[19] Ibid.
[20] Ibid.
[21] Ibid.